ឯកសារទិន្នន័យគម្រោង (PDS) ដែលបកប្រែនេះ គឺផ្អែកទៅតាមសំណៅភាសាអង់គ្លេសចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៤

ADB

# ឯកសារទិន្នន័យគម្រោង

ឯកសារទិន្នន័យគម្រោង (PDS) រួមមាន ព័ត៌មានសង្ខេបអំពីគម្រោង ឬកម្មវិធី ៖ ដោយសារតែ PDS គឺជាការងារដែលត្រូវធ្វើជាបន្តបន្ទាប់ ព័ត៌មានមួយចំនួនអាចមិនទាន់ត្រូវបានដាក់បញ្ចូលនៅក្នុងសំណៅដំបូងនេះនៅឡើយ ប៉ុន្តែនឹងត្រូវបន្ថែមនៅពេលដែលមាន ។ ព័ត៌មានអំពីគម្រោងដែលត្រូវបានស្នើឡើង គឺត្រឹមតែជាព័ត៌មានបណ្ដោះអាសន្នតែប៉ុណ្ណោះ ។

| កាលបរិច្ឆេទបង្កើត PDS | |
|---|---|
| PDS ត្រូវបានធ្វើបច្ចុប្បន្នកម្មត្រឹមកាលបរិច្ឆេទ | ៣១ មីនា ២០១៤ |

| | |
|---|---|
| ឈ្មោះគម្រោង | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតាមសហគមន៍ |
| ប្រទេស | ប្រទេសកម្ពុជា |
| លេខគម្រោង/កម្មវិធី | 46009-002 |
| ស្ថានភាព | ត្រូវបានស្នើឡើង |
| ទីតាំងភូមិសាស្ត្រ | – |

នៅក្នុងការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រប្រចាំប្រទេសណាក៏ដោយ ការផ្ដល់ហិរញ្ញប្បទានដល់គម្រោងណាមួយក៏ដោយ ឬការលើកឡើង ឬយោងលើដែនដី ឬតំបន់ភូមិសាស្ត្រណាមួយ នៅក្នុងឯកសារនេះ ធនាគារអភិវឌ្ឍន៍អាស៊ីមិនមានបំណងធ្វើការវិនិច្ឆ័យអំពីស្ថានភាពគតិយុត្តិ ឬស្ថានភាពដទៃទៀតរបស់ដែនដី ឬតំបន់នោះឡើយ ។

| | |
|---|---|
| ចំណាត់ថ្នាក់វិស័យ និង/ឬអនុវិស័យ | ពហុវិស័យ/ពហុវិស័យ |
| ចំណាត់ថ្នាក់ប្រធានបទ | ការអភិវឌ្ឍសង្គម |
| ប្រភេទនៃការបញ្ជ្រាបយេនឌ័រ | ការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព |

## ■ ការផ្ដល់ហិរញ្ញប្បទាន

| ប្រភេទ/ទម្រង់នៃការផ្ដល់ជំនួយ | លេខអនុម័ត | ប្រភពមូលនិធ | ចំនួនដែលត្រូវបានអនុម័ត (គិតជាពាន់) |
|---|---|---|---|
| ជំនួយឥតសំណង | - | - | 0 |
| **សរុប** | | | **0 ដុល្លារ** |

## ប្រភេទនៃគោលនយោបាយការពារផ្នែកបរិស្ថាន និងសង្គម

សម្រាប់ព័ត៌មានបន្ថែមស្តីពីប្រភេទនៃគោលនយោបាយការពារបរិស្ថាន និងសង្គម សូមមើល
http://www.adb.org/site/safeguards/safeguard-categories

| | |
|---|---|
| **បរិស្ថាន** | C |
| **ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត** | C |
| **ក្រុមជនជាតិដើមភាគតិច** | C |

## សង្ខេបបញ្ហាបរិស្ថាន និងសង្គម

**ទិដ្ឋភាពបរិស្ថាន**

ពុំមានផលប៉ះពាល់

**ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត**

ពុំមានផលប៉ះពាល់។ សមាសភាគ A និង B ពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍសមត្ថភាព ហើយសមាសភាគ D នឹងធ្វើឱ្យការគ្រប់គ្រងគម្រោងកាន់តែមានភាពល្អប្រសើរជាងមុន ហើយពុំមានសមាសភាគមួយណា ក្នុងចំណោមសមាសភាគទាំងបី ពាក់ព័ន្ធជាមួយនឹងការធ្វើលទ្ធកម្មដីធ្លី និងការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្តនោះទេ។ សមាសភាគ C: សកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតាមសហគមន៍ នឹងមានបញ្ចូលការស្តារឡើងវិញ ឬការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធកាត់បន្ថយហានិភ័យគ្រោះមហន្តរាយសម្រាប់គោលបំណងជាការដាក់បង្ហាញ។ ការងារស្តារឡើងវិញ នឹងធ្វើឡើងក្នុងក្របខ័ណ្ឌរចនាសម្ព័ន្ធសហគមន៍ ដែលមានស្រាប់ ហើយការស្ថាបនាថ្មីនានា នឹងធ្វើឡើងនៅលើដីទំនេររបស់រដ្ឋាភិបាល។ គម្រោងនេះនឹងមិនបង្កឱ្យមានការបាត់បង់លំនៅដ្ឋានឡើយ។

**ក្រុមជនជាតិដើមភាគតិច**

ការអភិវឌ្ឍសមត្ថភាព ការកែលំអការគ្រប់គ្រងគម្រោង និងសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់ នៅក្នុងតំបន់គម្រោង។ សេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស ប្រព័ន្ធប្រកបរបរចិញ្ចឹមជីវិត វប្បធម៌ ឬធនធានរបស់អ្នកទទួលផល នឹងមិនទទួលរងផលប៉ះពាល់ជាអវិជ្ជមាន ដោយសារតែគម្រោងនេះឡើយ។

## ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

### ក្នុងកំឡុងពេលរៀបចំគម្រោង

ជាផ្នែកមួយនៃដំណើរការរៀបចំគម្រោង ការរៀបចំផែនទីបង្ហាញពីសកម្មភាពបច្ចុប្បន្ន ដែលពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានធ្វើឡើង។ ទីប្រឹក្សារបស់ ADB បានធ្វើការសម្ភាសជាមួយនឹងអង្គការអភិវឌ្ឍន៍នានាដែលពាក់ព័ន្ធ (ដូចជា ទីភ្នាក់ងារសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយនានា) ដែលមានឯកទេស ឬដែលកំពុងអនុវត្តគម្រោងឆ្លើយតបមនុស្សធម៌ គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឬគម្រោងស្តារឡើងវិញក្រោយគ្រោះមហន្តរាយកើតឡើង។ បន្ថែមពីលើការងារគ្រប់គ្រងគ្រោះមហន្តរាយ ដែលកំពុងធ្វើនាពេលបច្ចុប្បន្ននេះ អ្នកតបសំណួរបានផ្តល់ព័ត៌មានត្រឡប់អំពីការចូលរួមបំពេញការងាររបស់ពួកគេ ជាមួយនឹង NCDM និងក្រសួងពាក់ព័ន្ធនានា និងបានលើកឡើងពីផ្នែក ដែលការសម្របសម្រួលការងារគ្រោះមហន្តរាយរបស់ប្រទេសនេះ អាចកែលំអបាន។ អង្គការទាំងនេះក៏បានកំណត់ពីផ្នែកបច្ចេកទេស ដែលគេអាចប្រើប្រាស់ជំនាញរបស់ខ្លួន សម្រាប់សកម្មភាពកសាងសមត្ថភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការចូលរួមបំពេញការងារដោយផ្ទាល់ ជាមួយនឹងគម្រោងនេះ ឬការធ្វើសកម្មភាព ដោយឯករាជ្យខ្លួនឯង។ លើសពីនេះ ការរៀបចំគម្រោងនេះក៏ទទួលបានព័ត៌មានពីលទ្ធផលនៃការវាយតម្លៃសមត្ថភាពស្ថាប័ន NCDM និងអង្គភាពថ្នាក់ក្រោមជាតិរបស់ NCDM ផងដែរ។ ការសម្ភាសនានា ត្រូវបានធ្វើឡើង ជាមួយនឹងមន្ត្រីរបស់ NCDM មកពីគ្រប់នាយកដ្ឋានទាំងអស់ និងជាមួយមន្ត្រីមកពីតាមក្រសួងពាក់ព័ន្ធ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំណុចនានា ដែលត្រូវបានលើកយកមកពិភាក្សា រួមមានការប្រាស្រ័យទាក់ទងអន្តរវិស័យ និងសកម្មភាពដែលអនុវត្តក្នុងលក្ខណៈជាបុគ្គល ឬរួមគ្នា ពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងគ្រោះមហន្តរាយ។ លទ្ធផលនៃការវាយតម្លៃនេះ ត្រូវបានបង្ហាញទៅកាន់ NCDM កាលពីខែ មីនា ឆ្នាំ ២០១៣ ហើយសកម្មភាពក្នុងគម្រោងដែលស្នើឡើងនេះ ត្រូវបានវាយតម្លៃឃើញថា មានភាពឆ្លើយតប ចំពោះបញ្ហា ដែលបានលើកឡើង។ កិច្ចប្រជុំពិគ្រោះយោបល់រួមគ្នាមួយ រវាងទីភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានធ្វើឡើង កាលពីថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៣ ដើម្បីពិនិត្យឡើងវិញលើសកម្មភាព ដែលបានស្នើឡើង ស្វែងរកការសហការគ្នា អនុវត្តសកម្មភាពផ្គួបកម្លាំងគ្នា និងចៀសវាងការធ្វើការងារត្រួតគ្នា។

### ក្នុងកំឡុងពេលអនុវត្តគម្រោង

នៅក្នុងកំឡុងពេលអនុវត្តគម្រោងនេះ កិច្ចប្រជុំសម្របសម្រួល និងការចែករំលែកព័ត៌មានជាទៀងទាត់ នឹងត្រូវធ្វើឡើងជាមួយអ្នកពាក់ព័ន្ធនានា ដូចជា ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីលើកកម្ពស់ការផ្គួបកម្លាំងគ្នា រវាងគម្រោង និងគម្រោង និងបញ្ចៀសមិនឱ្យមានការធ្វើការងារត្រួតគ្នា។

## សេចក្តីពិពណ៌នា

ផលរយៈពេលវែងរបស់គម្រោង: កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន ដែលបង្កឡើងដោយគ្រោះទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងទៀតមកលើសហគមន៍ងាយរងគ្រោះជាងគេ នៅក្នុងប្រទេសកម្ពុជា។ លទ្ធផលរយៈពេលមធ្យមៈ សមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយ នៅថ្នាក់ស្រុក និងឃុំ ត្រូវបានពង្រឹង។ លទ្ធផលគម្រោងៈ ១. បង្កើនសមត្ថភាពស្ថាប័ន និងបច្ចេកទេសរបស់ស្រុកអាទិភាពខាងផ្នែកកាត់បន្ថយ និងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ២. លើកកម្ពស់សមត្ថភាពកាត់បន្ថយ និងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ របស់ឃុំគោលដៅ ៣. សកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតាមសហគមន៍ ត្រូវបានអនុវត្ត និង ៤. ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធភាព។

## សនិទានភាព និងទំនាក់ទំនងរបស់គម្រោងជាមួយនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់

ប្រទេសកម្ពុជាទទួលរងគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ ដែលបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋក្រីក្រជាច្រើនគ្រួសារ ជារៀងរាល់ឆ្នាំ។ នៅក្នុងឆ្នាំ ២០០៩ ព្យុះកំបត់ត្បូងកេតសាណា បានបង្កផលប៉ះពាល់ដល់ខេត្តចំនួន ១១ ក្នុងចំណោមរាជធានី-ខេត្តទាំង ២៤ ដែលនាំឱ្យមានការខូចខាតសរុបចំនួន ៣៩ លានដុល្លារ (NCDM 2009)។ នៅក្នុងឆ្នាំ ២០១១ ប្រទេសកម្ពុជាទទួលរងគ្រោះដោយសារភ្លៀងធ្លាក់ខ្លាំង អូសបន្លាយពេលយូរ (ពីខែ សីហា ដល់ខែ តុលា) ដែលនាំឱ្យមានគ្រោះទឹកជំនន់ ដែលមិនធ្លាប់កើតមានកន្លងមក នៅក្នុងខេត្តចំនួន ១៨ ក្នុងចំណោមរាជធានី-ខេត្តទាំង ២៤។ ទឹកជំនន់មានផលប៉ះពាល់ធំធេងមកលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសហគមន៍ជាច្រើន ដែលនាំឱ្យមនុស្សចំនួន ២៥០ នាក់ បាត់បង់ជីវិត ខូចខាតអស់ទឹកប្រាក់ចំនួន ៦២៥ លានដុល្លារ និងបង្កផលប៉ះពាល់ដល់មនុស្សចំនួន ១.៥ លាននាក់ (ADB 2012)។ ស្របពេលដែលស្ថានភាពអាកាសធាតុសកលបន្តមានការប្រែប្រួល ប្រទេសកម្ពុជានឹងជួបប្រទះគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលមិនអាចព្យាករដឹងមុនបាន កាន់តែច្រើនឡើងៗ ដែលអាចហួសពីសមត្ថភាព និងធនធានមានកម្រិតរបស់ប្រទេសនេះ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ដែលត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ ១៩៩៥ គឺជាទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយសំខាន់ជាងគេមួយ ដែលមាននាទីធ្វើការសម្របសម្រួលការឆ្លើយតបអន្តរក្រសួង ចំពោះស្ថានភាពអាសន្ន និងគ្រោះមហន្តរាយនានា។ ជាផ្នែកមួយនៃការបន្តវិនិយោគរបស់ខ្លួនលើការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងការស្តារឡើងវិញ ADB បានរៀបចំឱ្យមានការពិនិត្យឡើងវិញលើស្ថាប័ន និងការវាយតម្លៃសមត្ថភាពរបស់ NCDM។ ការវាយតម្លៃនេះ រួមមាន ការពិនិត្យឡើងវិញលើគោលនយោបាយ រចនាសម្ព័ន្ធ ការបំពេញការងារ និងលទ្ធផលរបស់ NCDM តាមរយៈការសម្ភាសជាលក្ខណៈបុគ្គល ជាមួយនឹងមន្ត្រីរបស់ NCDM ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាការពិនិត្យលើទិន្នន័យក្នុងឯកសារពាក់ព័ន្ធ និងការសង្កេតមើលកិច្ចប្រជុំសម្របសម្រួល នៅក្នុងរយៈពេល ៦ ខែ។ របកគំហើញនានាបង្ហាញថា ប្រតិបត្តិការរបស់ NCDM ជួបប្រទះការលំបាកខ្លាំង ដោយសារ

តែរចនាសម្ព័ន្ធស្ថាប័ន ដែលមិនបំពេញមុខងារ ដោយមូលហេតុចម្បង គឺកង្វះធនធានហិរញ្ញវត្ថុ។ នៅថ្នាក់ជាតិ កិច្ចប្រជុំរបស់ NCDM មិនបានធ្វើឡើងជាទៀងទាត់នោះ ទៅតាមអណត្តិដែលកំណត់នោះឡើយ ហើយនៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ ក្រសួង និងអ្នកពាក់ព័ន្ធនានារបស់រដ្ឋាភិបាល ជួបប្រជុំគ្នា តែក្រោយពេលដែលស្ថានភាពអាសន្ន និងគ្រោះមហន្តរាយនានាកើតមានឡើង តែប៉ុណ្ណោះ។ អគ្គលេខាធិការដ្ឋាន NCDM ក៏មិនបានដំណើរការទៅប្រកបដោយប្រសិទ្ធភាពនោះដែរ។ ទាំងអគ្គលេខាធិការដ្ឋាន NCDM ទាំងនាយកដ្ឋានប្រតិបត្តិការរបស់ស្ថាប័ននេះ មិនបានរៀបចំផែនការសកម្មភាព ឬផែនការប្រតិបត្តិរបស់ខ្លួន ឬពុំមានថវិកាប្រតិបត្តិការប្រចាំឆ្នាំ សម្រាប់ផែនការទាំងនេះ។ នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ បានទទួលការទទួលខុសត្រូវ ក្នុងការដឹកនាំការងារគ្រប់គ្រងគ្រោះមហន្តរាយ នៅតាមកម្រិតរដ្ឋបាលរៀងៗខ្លួន ដោយមិនបានទទួលធនធាន ឱ្យបានគ្រប់គ្រាន់នោះឡើយ។ ស្ថានភាព នៅថ្នាក់ក្រោមជាតិ តាមពិតទៅ កាន់តែមានការលំបាកទៅទៀត ដោយហេតុថា ពួកគេ គឺជាអ្នកនៅជួរមុខគេ ដែលត្រូវឆ្លើយតបដោយផ្ទាល់ចំពោះផលប៉ះពាល់នានា ដែលកើតមានឡើងដោយសារស្ថានភាពអាសន្ន និងគ្រោះមហន្តរាយនានា។ ប្រតិបត្តិការរបស់ពួកគេ ក៏ជួបប្រទះនឹងការលំបាកផងដែរ ដោយសារតែការមិនមានគោលការណ៍ណែនាំ និងនីតិវិធីស្តង់ដាប្រតិបត្តិការ (SOPs) ដែលមានភាពច្បាស់លាស់ ដែលមានចែងពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ចំពោះគ្នាទៅវិញទៅមក (ដូចជា PCDM-DCDM-CCDM ជាដើម) រួមជាមួយនឹង NCDM និងអង្គការក្នុងស្រុក និងអន្តរជាតិនានា ដែលតែងឆ្លើយតបចំពោះស្ថានភាពអាសន្ន និងគ្រោះមហន្តរាយ។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ បច្ចុប្បន្ន ទទួលស្គាល់ការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងទំនាក់ទំនងទៅវិញទៅមករវាងការងារនេះ ជាមួយនឹងភាពក្រីក្រ នៅក្នុងប្រទេស។ ការពង្រឹងភាពធន់របស់សហគមន៍ ចំពោះគ្រោះមហន្តរាយ គួរជារបៀបវារៈជាអាទិភាពមួយ ដោយសារតែវាចូលរួមចំណែកចំពោះការកាត់បន្ថយភាពក្រីក្រ និងចំពោះការលើកកម្ពស់គុណភាពជីវិតជាទូទៅ ដែលជាគោលបំណងចម្បងរបស់រដ្ឋាភិបាល។ ការដាក់ឱ្យអនុវត្តនូវការវាយតម្លៃលើមុខសញ្ញាគ្រោះថ្នាក់ និងភាពងាយរងគ្រោះ ប្រព័ន្ធផ្តល់ព័ត៌មានជាមុន ផែនការឆ្លើយតបចំពោះស្ថានភាពអាសន្ន និងផែនការត្រៀមបង្ការ និងស្តារឡើងវិញក្នុងសហគមន៍ នឹងផ្តល់លទ្ធភាពឱ្យសហគមន៍មូលដ្ឋាន ឆ្លើយតបផ្ទាល់ចំពោះភាពងាយរងគ្រោះជាក់លាក់របស់ពួកគេ និងផ្តោតសំខាន់លើកត្តាចម្បង ដែលរួមចំណែកនាំឱ្យមានភាពក្រីក្រ នៅក្នុងប្រទេសនេះ។ យុទ្ធសាស្រ្តឆ្នាំ ២០២០ របស់ ADB ដាក់បញ្ចូលការប្តេជ្ញាចិត្ត ក្នុងការផ្តល់ការគាំទ្រជាជំនួយ សម្រាប់គ្រោះមហន្តរាយ និងស្ថានភាពអាសន្ន រួមជាមួយនឹងការគាំទ្រសម្រាប់វិស័យសំខាន់ៗ ដូចជា ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្រ្តភាពជាដៃគូប្រចាំប្រទេសបច្ចុប្បន្ន (២០១១-២០១៣) របស់ ADB ផ្តោតចម្បងលើបញ្ហាប្រឈមអន្តរវិស័យ ពាក់ព័ន្ធជាមួយនឹងបរិស្ថាន និងការប្រែប្រួលអាកាសធាតុ និងវិមជ្ឈការ និងវិសហមជ្ឈការ (D&D) និងរៀបចំឡើង ផ្អែកទៅតាមព័ត៌មាន ដែលទទួលបានពីការសិក្សាវាយតម្លៃពិសេសលើការឆ្លើយតបរបស់ ADB ចំពោះគ្រោះមហន្តរាយធម្មជាតិ និងគ្រោះភ័យនៃគ្រោះមហន្តរាយ។ ADB កំពុងផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការរៀបចំសំណើចំនួន ២ ដែលនឹងផ្តោតការយកចិត្តទុកដាក់លើបញ្ហាដែលមានស្រាប់ និងលើចំណុចខ្សោយផ្នែករចនាសម្ព័ន្ធ ពាក់ព័ន្ធជាមួយ នឹងសមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយរបស់ប្រទេសនេះ ដូចជា (i)

គម្រោងជំនួយបច្ចេកទេស ដើម្បីដោះស្រាយបញ្ហាគ្រប់គ្រង គ្រោះមហន្តរាយ នៅថ្នាក់ជាតិ (គោលនយោបាយ) នៅថ្នាក់លេខាធិការដ្ឋាន NCDM និងនៅថ្នាក់ខេត្ត និង (ii) គម្រោងជំនួយឥតសំណង (គម្រោងនេះតែម្តង) ដែលនឹងបំពេញបន្ថែម ដល់ការពង្រឹងស្ថាប័ន ដែលបានគ្រោងទុក ដោយរៀបចំការងារសម្របសម្រួល និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ តាមរយៈរចនាសម្ព័ន្ធមូលដ្ឋាន នៅថ្នាក់ស្រុក និងថ្នាក់ឃុំ។ លក្ខណៈពហុកម្រិត នៃការកសាងសមត្ថភាពរបស់គម្រោង ដែលលើកស្នើឡើងនេះ ស្ថិតនៅក្រោមប្រធានបទការគ្រប់គ្រងវិស័យសាធារណៈ ដែលជាមូលដ្ឋាន សម្រាប់កែលំអប្រតិបត្តិការរបស់គម្រោង នៅក្នុងរាល់វិស័យគោលដៅទាំងអស់របស់ ADB។ លើសពីនេះ ជាផ្នែកមួយនៃការគាំទ្ររបស់ ADB ចំពោះរបៀបវារៈវិមជ្ឈការរបស់រដ្ឋាភិបាល ADB ប្តេជ្ញាធ្វើការងារ ជាមួយនឹងរចនាសម្ព័ន្ធវិមជ្ឈការ ដែលបង្កើតឡើងថ្មីៗ ឬដែលមានស្រាប់។

## ផលប៉ះពាល់នៃការអភិវឌ្ឍ

លើកកម្ពស់ការត្រៀមបង្ការ នៅថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បីឆ្លើយតបចំពោះគ្រោះមហន្តរាយធម្មជាតិ នៅក្នុងប្រទេសកម្ពុជា។

## លទ្ធផលរយៈពេលមធ្យមរបស់គម្រោង

| សេចក្តីពិពណ៌នាអំពីលទ្ធផលរយៈពេលមធ្យម | វឌ្ឍនភាពឆ្ពោះទៅសម្រេចលទ្ធផលរយៈពេលមធ្យម |
|---|---|
| លើកកម្ពស់ការគ្រប់គ្រងគ្រោះមហន្តរាយ និងសមត្ថភាពឆ្លើយតប នៅថ្នាក់ស្រុក និងឃុំ ដើម្បីដោះស្រាយបញ្ហាគ្រោះមហន្តរាយធម្មជាតិ | - |

## លទ្ធផល និងវឌ្ឍនភាពនៃការអភិវឌ្ឍ

| សេចក្តីពិពណ៌នាអំពីលទ្ធផលរបស់គម្រោង | ស្ថានភាពនៃការអនុវត្ត (លទ្ធផល សកម្មភាព និងបញ្ហា) |
|---|---|
| សមត្ថភាពស្ថាប័ន និងបច្ចេកទេសខាងការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយរបស់ស្រុកអាទិភាព ត្រូវបានលើកកម្ពស់។ សមត្ថភាពរបស់ឃុំគោលដៅ ក្នុងការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយត្រូវបានលើកកម្ពស់។ សកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងបន្សាំទៅនឹងការប្រែ | - |

ប្រែប្រួលអាកាសធាតុតាមសហគមន៍ ត្រូវបានអនុវត្ត។ ការគ្រប់គ្រង
គម្រោងត្រូវបានធ្វើឡើង ប្រកបដោយប្រសិទ្ធភាព។

| **ស្ថានភាពនៃគោលដៅអភិវឌ្ឍ** | **ការផ្លាស់ប្តូរសំខាន់ៗ** |
| --- | --- |
| | |

## ឱកាសធុរកិច្ច

**កាលបរិច្ឆេទនៃការចុះបញ្ជីដំបូង** 6 Feb 14

**សេវាពិគ្រោះយោបល់**

ជំនួយឥតសំណងនេះ ត្រូវការការបំពេញការងាររបស់ទីប្រឹក្សាជាតិចំនួន ១៩៨ នាក់-ខែ ដែលត្រូវជួលឱ្យបំពេញការងារ តាមរយៈដំណើរការជ្រើសរើសទីប្រឹក្សាជាលក្ខណៈបុគ្គល (ICS) ស្របទៅតាមគោលការណ៍ណែនាំរបស់ ADB ស្តីពីការប្រើប្រាស់ទីប្រឹក្សា (ឆ្នាំ ២០១៣ និងធ្វើវិសោធនកម្ម ជាបន្តបន្ទាប់)

**លទ្ធកម្ម**

មានកិច្ចសន្យាសាងសង់ជាទ្រង់ទ្រាយតូច នៅថ្នាក់ស្រុក ហើយសម្ភារឧបករណ៍នានា ត្រូវទិញ ដោយប្រើប្រាស់នីតិវិធីដើរទិញ (shopping procedure)។

**សេចក្តីជូនដំណឹងអំពីលទ្ធកម្ម និងការពិគ្រោះយោបល់**

http://www.adb.org/projects/46009-002/business-opportunities

## កាលវិភាគ

| | |
| --- | --- |
| **ការឯកភាពលើទស្សនទាន** | ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៣ |
| **ការស្វែងរកការពិត** | ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៣ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៣ |
| **កិច្ចប្រជុំពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង** | - |
| **ការអនុម័ត** | - |
| **បេសកកម្មពិនិត្យឡើងវិញចុងក្រោយ** | - |

## ■ ចំណុចដៅ

| លេខអនុម័ត | ការអនុម័ត | ចុះហត្ថលេខា | ចូលជាធរមាន | បិទ | | |
|---|---|---|---|---|---|---|
| | | | | សំណៅដើម | ត្រូវបានកែសម្រួល | ជាក់ស្តែង |
| - | - | - | - | - | - | - |

## ■ ការប្រើប្រាស់

| កាលបរិច្ឆេទ | ការអនុម័តលេខ | ADB (ពាន់ US$) | ផ្សេងៗទៀត (ពាន់ US$) | ភាគរយសុទ |
|---|---|---|---|---|
| ចំនួនសរុបក្នុងការផ្តល់កិច្ចសន្យា | | | | |
| - | - | - | - | - |
| ការបើកប្រាក់សរុប | | | | |
| - | - | - | - | - |

## ■ ស្ថានភាពនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងត្រូវបានបែងចែកតាមប្រភេទដូចតទៅ - របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោងដែលត្រូវបានធ្វើសវនកម្មរួច ការគាំពារបរិស្ថាន សង្គម កិច្ចការសង្គម កិច្ចការវិស័យហិរញ្ញវត្ថុ សេដ្ឋកិច្ច និងកិច្ចការផ្សេងៗទៀត។ ការអនុលោមទៅតាមកិច្ចព្រមព្រៀង ត្រូវបានដាក់ពិន្ទុទៅតាមប្រភេទ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចតទៅ: (១) ពេញចិត្តៈ អនុលោមទាំងអស់ទៅតាមគ្រប់កិច្ចព្រមព្រៀង ដោយមានករណីលើកលែងច្រើនបំផុតត្រឹម ១ ដែលអនុញ្ញាតឱ្យមាន (២) ពេញចិត្តដោយអន្លឺះ ច្រើនបំផុត មានកិច្ចព្រមព្រៀងចំនួន ២ ដែលមិនត្រូវបានអនុលោមតាម (៣) មិនពេញចិត្តៈ មានកិច្ចព្រមព្រៀងចាប់ពី ៣ ឡើងទៅដែលមិនត្រូវបានអនុលោមតាម។ យោងតាមគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈឆ្នាំ ២០១១ ការវាយតម្លៃនៃភាពអនុលោមរបស់កិច្ចព្រមព្រៀង សម្រាប់របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោង អនុវត្តតែចំពោះគម្រោង ដែលលិខិតអញ្ជើញឱ្យចរចាក្រោយថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ តែប៉ុណ្ណោះ។

| ការអនុម័តលេខ | ប្រភេទ | | | | | | |
|---|---|---|---|---|---|---|---|
| | វិស័យ | សង្គម | ហិរញ្ញវត្ថុ | សេដ្ឋកិច្ច | ផ្សេងៗ | ការគាំពារបរិស្ថានសង្គម | របាយការណ៍ហិរញ្ញវត្ថុរបស់គម្រោង |
| ជំនួយឥតសំណង- | - | - | - | - | - | - | - |

## ផ្នែកទំនាក់ទំនង និងព័ត៌មានបច្ចុប្បន្នភាព

| | |
|---|---|
| **មន្ត្រី ADB ដែលទទួលខុសត្រូវ** | ហែម ចាន់ធូ (chem@adb.org) |
| **នាយកដ្ឋាន ADB ដែលទទួលខុសត្រូវ** | នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| **ការិយាល័យ ADB ដែលទទួលខុសត្រូវ** | ស្ថានបេសកកម្មប្រចាំប្រទេសកម្ពុជា |
| **ទីភ្នាក់ងារប្រតិបត្តិ** | |

## ឯកសារសម្រាប់មើលព័ត៌មានផ្សេងៗទៀត

| | |
|---|---|
| **គេហទំព័ររបស់គម្រោង** | http://www.adb.org/projects/46009-002/main |
| **បញ្ជីឯកសារគម្រោង** | http://www.adb.org/projects/46009-002/documents |